ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៥៦៥ សហវ.ប្រក

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការកែសម្រួល និងកំណត់គោលការណ៍ទូទាត់ សម្រាប់លើកទឹកចិត្តក្រុមការងារប្រយុទ្ធនឹងជំងឺកូវីដ-១៩

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** **រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

Scanned with CamScanner

- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៨៥ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៦៧ សសរ. ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៦៨ សសរ. ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការតែងតាំងសមាសភាពគណៈប្រចាំការនៃគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៦៩ សសរ. ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២១ ស្តីពីសមាសភាព និង ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៧០ សសរ. ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការតែងតាំងសមាសភាពនៃអនុគណៈកម្មការនានាចំណុះឱ្យគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៨០ សសរ. ចុះថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការបង្កើតអនុគណៈកម្មការដឹកនាំការអនុវត្តច្បាប់ចំណុះឱ្យគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៣៧ សសរ. ចុះថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០២១ ស្តីពីការបង្កើតគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសុខាភិបាល

## សម្រេច

**ប្រការ១.-**

ត្រូវបានកែសម្រួល និងកំណត់គោលរបបឧបត្ថម្ភលើកទឹកចិត្តក្រុមការងារប្រយុទ្ធនឹងជំងឺកូវីដ-១៩ ដូចខាងក្រោម÷

| ល.រ | បរិយាយ | គោលរបប |
|---|---|---|
| **ក** | **ក្រុមការងារនៅមន្ទីរពេទ្យ ឬ មណ្ឌលព្យាបាលជំងឺកូវីដ-១៩ ឬ មណ្ឌលចត្តាឡីស័ក (QC2)** | |
| ១ | ក្រុមការងារនៅមន្ទីរពេទ្យ ឬមណ្ឌលព្យាបាល អំឡុងពេលពិនិត្យ ថែទាំ ព្យាបាលជំងឺ | |
| | ក្រុមគ្រូពេទ្យ អំឡុងពេលពិនិត្យ ថែទាំព្យាបាល | ២០០ ០០០ រៀល/នាក់/ថ្ងៃ |
| | បុគ្គលិកអនាម័យ និងកម្មករ អំឡុងពេលពិនិត្យ ថែទាំ ព្យាបាល | ១៤០ ០០០ រៀល/នាក់/ថ្ងៃ |
| | ថ្លៃអាហារក្រុមគ្រូពេទ្យ បុគ្គលិកអនាម័យ និងកម្មករ អំឡុងពេលពិនិត្យ ថែទាំ ព្យាបាល | ៦០ ០០០ រៀល/នាក់/ថ្ងៃ |
| ២ | ក្រុមការងារនៅមន្ទីរពេទ្យ ឬមណ្ឌលព្យាបាល អំឡុងពេលធ្វើចត្តាឡីស័ក ១៤ ថ្ងៃ | |



CS Scanned with CamScanner

| | | |
|---|---|---|
| | ក្រុមគ្រូពេទ្យ អំឡុងពេលធ្វើចត្តាឡីស័ក ១៤ថ្ងៃ | ១០០ ០០០ រៀល/នាក់/ថ្ងៃ |
| | បុគ្គលិកអនាម័យ និងកម្មករ អំឡុងពេលធ្វើចត្តាឡីស័ក ១៤ ថ្ងៃ | ៧០ ០០០ រៀល/នាក់/ថ្ងៃ |
| | ថ្លៃអាហារក្រុមគ្រូពេទ្យ បុគ្គលិកអនាម័យ និងកម្មករ អំឡុងពេលធ្វើចត្តាឡីស័ក ១៤ ថ្ងៃ | ៤០ ០០០ រៀល/នាក់/ថ្ងៃ |
| ៣ | ក្រុមការងារ នៅមណ្ឌលចត្តាឡីស័ក ១៤ថ្ងៃ (QC2) | |
| | ក្រុមគ្រូពេទ្យ ពេលពិនិត្យ ថែទាំ ព្យាបាល នៅមណ្ឌលចត្តាឡីស័ក ១៤ថ្ងៃ (QC2) | ១៤០ ០០០ រៀល/នាក់/ថ្ងៃ |
| | បុគ្គលិកអនាម័យ ដែលប្រចាំការនៅមណ្ឌលចត្តាឡីស័ក ១៤ថ្ងៃ (QC2) | ៧០ ០០០ រៀល/នាក់/ថ្ងៃ |
| **ខ** | **ក្រុមការងារនៃមន្ទីរពិសោធន៍សាធារណៈ តេស្តរកមេរោគកូវីដ-១៩ ដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល** | |
| | មន្ត្រីមន្ទីរពិសោធន៍ធ្វើតេស្តវីរុស | ២០០ ០០០ រៀល/នាក់/ថ្ងៃ |
| | បុគ្គលិកអនាម័យ | ១៤០ ០០០ រៀល/នាក់/ថ្ងៃ |
| **គ** | **ក្រុមឆ្លើយតបបន្ទាន់ (RRT) ចុះស៊ើបអង្កេតអ្នកប៉ះពាល់ និងយកសំណាក ដែលក្នុងមួយក្រុម មានសមាជិកចំនួន ០៤នាក់ និងអ្នកបើកបររថយន្ត ០១នាក់** | |
| | មន្ត្រី RRT | ២០០ ០០០ រៀល/នាក់/ថ្ងៃ |
| | អ្នកបើកបររថយន្ត | ១៤០ ០០០ រៀល/នាក់/ថ្ងៃ |
| **ឃ** | **ក្រុមការងារសម្របសម្រួល និងទទួលបន្ទុកខ្សែទូរស័ព្ទទាន់ហេតុការណ៍** | |
| ១ | ក្រុមការងារសុខាភិបាលសម្របសម្រួលនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ, មន្ត្រីទទួលបន្ទុកខ្សែទូរស័ព្ទទាន់ហេតុការណ៍ (១១៥) ដែលមានភារកិច្ចផ្តល់ប្រឹក្សា និងទំនាក់ទំនងសាធារណៈក្នុងការផ្តល់ព័ត៌មាន និងឆ្លើយតបជំងឺកូវីដ-១៩ | ១០០ ០០០ រៀល/នាក់/ថ្ងៃ |
| ២ | ក្រុមសម្របសម្រួលនិងប្រចាំការនៅទីស្តីការក្រសួងសុខាភិបាល | ៦០ ០០០ រៀល/នាក់/ថ្ងៃ |
| ៣ | ក្រុមសម្របសម្រួលនិងប្រចាំការនៅមន្ទីរសុខាភិបាលរាជធានី-ខេត្ត ត្រូវមានសមាជិកយ៉ាងច្រើន ៥នាក់ | ៦០ ០០០ រៀល/នាក់/ថ្ងៃ |
| ៤ | ក្រុមការងារខ្សែទូរស័ព្ទទាន់ហេតុការណ៍នៅថ្នាក់រាជធានី-ខេត្ត និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ | របបប្រចាំថ្ងៃ ឬ ប្រចាំខែ រដ្ឋបាលរាជធានី-ខេត្ត ទទួលរ៉ាប់រង |
| **ង** | **ក្រុមផ្តល់សេវាព្យាបាលតាមផ្ទះ** | |
| ១ | ប្រើប្រាស់ក្រុមការងារ Hotline រាជធានី-ខេត្ត | ១ ០០០ ០០០ រៀល/នាក់/ខែ |
| ២ | ប្រើប្រាស់ក្រុមមន្ត្រីសុខាភិបាលនៅកម្រិតស្រុក-ខណ្ឌ | អាជ្ញាធរមូលដ្ឋានទទួលរ៉ាប់រង |
| **ច** | **មន្ត្រីចត្តាឡីស័កប្រចាំការ** | |
| | មន្ត្រីចត្តាឡីស័កប្រចាំការនៅអាកាសយានដ្ឋានអន្តរជាតិ នៅកំពង់ផែអន្តរជាតិ និងនៅច្រកទ្វារចេញ-ចូលប្រទេស | ១៤០ ០០០ រៀល/នាក់/ថ្ងៃ |



CS Scanned with CamScanner

| | | |
|---|---|---|
| **ង** | **ថ្លៃបបរអាហារអ្នកជំងឺ** | |
| | ថ្លៃបបរអាហារសម្រាប់អ្នកជំងឺកូវីដ-១៩ នៅរាជធានីភ្នំពេញ និងខេត្ត | ៣០ ០០០ រៀល/នាក់/ថ្ងៃ |
| **ច** | **អំពីគោលរបបឧបត្ថម្ភក្រុមគោលដៅ ដែលនៅជួរមុខប្រយុទ្ធនឹងជំងឺកូវីដ-១៩** | |
| ១ | ប្រធានមន្ទីរពេទ្យ ឬ ប្រធានមណ្ឌលព្យាបាលជំងឺកូវីដ-១៩ | ៦ ០០០ ០០០ រៀល/នាក់/ខែ |
| ២ | អនុប្រធានមន្ទីរពេទ្យ ឬ អនុប្រធានមណ្ឌលព្យាបាលជំងឺកូវីដ-១៩ ដោយកម្រិតចំនួនអនុប្រធានយ៉ាងច្រើនត្រឹម ៣នាក់ | ៥ ០០០ ០០០ រៀល/នាក់/ខែ |
| ៣ | ប្រធានការិយាល័យ ប្រធានផ្នែក ឬ ប្រហាក់ប្រហែល | ៣ ១៥០ ០០០ រៀល/នាក់/ខែ |
| ៤ | អនុប្រធានផ្នែក ឬ ប្រហាក់ប្រហែល ចុះក្រោម រួមទាំង បុគ្គលិកគណនេយ្យ, បុគ្គលិករដ្ឋបាល, អ្នកគ្រប់គ្រងឃ្លាំងឱសថ និងបរិក្ខារ, អ្នកគ្រប់គ្រងឃ្លាំងសម្ភារទូទៅ | ២ ១០០ ០០០ រៀល/នាក់/ខែ |
| ៥ | អ្នកបើកបររថយន្តគិលានសង្គ្រោះ (Ambulance) | ១៤០ ០០០ រៀល/នាក់/ថ្ងៃ |
| **ឆ** | **អំពីគោលរបបឧបត្ថម្ភក្រុមគោលដៅធ្វើចត្តាឡីស័ក** | |
| ១ | របបថ្លៃអាហារ សម្រាប់ពលករធ្វើចត្តាឡីស័កមកតាមច្រកព្រំដែនផ្លូវគោកនិងផ្លូវទឹក | ២០ ០០០ រៀល/នាក់/ថ្ងៃ |
| ២ | របបថ្លៃអាហារ សម្រាប់ពលករធ្វើចត្តាឡីស័កមកតាមយន្តហោះ | ៤០ ០០០ រៀល/នាក់/ថ្ងៃ |
| ៣ | របបថ្លៃស្នាក់នៅ សម្រាប់ពលករធ្វើចត្តាឡីស័កមកតាមយន្តហោះ | ៦០ ០០០ រៀល/នាក់/ថ្ងៃ |
| ៤ | អ្នកបើកបរដឹកជញ្ជូនពលករចេញពីមណ្ឌលចត្តាឡីស័ក ឬ មណ្ឌលព្យាបាលនៅព្រំដែន ទៅតាមបណ្តាខេត្ត | ៤០ ០០០ រៀល/នាក់/ថ្ងៃ |
| ៥ | អ្នកធ្វើចត្តាឡីស័ក នៅតាមសហគមន៍ និង អង្គភាពនានាទាំងរដ្ឋ និង ឯកជន | អាជ្ញាធរមូលដ្ឋាន និង អង្គភាពពាក់ព័ន្ធ ទទួលរ៉ាប់រង |
| **ជ** | **ក្រុមការងារចាក់វ៉ាក់សាំងកូវីដ-១៩** | |
| ១ | ក្រុមការងារចាក់វ៉ាក់សាំងខាងកងទ័ព | ៤ ០០០ រៀល/ដូស |
| ២ | ក្រុមការងារចាក់វ៉ាក់សាំងបុគ្គលិកក្របខណ្ឌ | ៤០ ០០០ រៀល/នាក់/ថ្ងៃ |
| ៣ | ក្រុមការងារគ្រូពេទ្យយុវជនស្ម័គ្រចិត្ត ចុះចាក់វ៉ាក់សាំងនៅភ្នំពេញ | ៨០ ០០០ រៀល/នាក់/ថ្ងៃ |
| ៤ | ក្រុមការងារគ្រូពេទ្យយុវជនស្ម័គ្រចិត្ត ចុះចាក់វ៉ាក់សាំងតាមខេត្ត | ១២០ ០០០ រៀល/នាក់/ថ្ងៃ |

**ប្រការ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។ ទន្ទឹមនេះ ត្រូវបាននិរាករណ៍លិខិតបទដ្ឋានគតិយុត្តដូចខាងក្រោម÷

- លិខិតលេខ ២៤៣៦ សហវ.អថ ចុះថ្ងៃទី២ ខែមេសា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីសំណើសុំគោលការណ៍អនុញ្ញាតការផ្តល់ប្រាក់ឧបត្ថម្ភជូនក្រុមការងារសុខាភិបាល និងសកម្មភាពពាក់ព័ន្ធផ្សេងទៀតសម្រាប់ទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩



CS Scanned with CamScanner

- លិខិតលេខ ២៦៩៥ សហវ.អថ ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់គោលការណ៍ប្រាក់ឧបត្ថម្ភលើកទឹកចិត្តបន្ថែម សម្រាប់ក្រុមគ្រូពេទ្យជួរមុខប្រយុទ្ធនឹងការរីករាលដាលជំងឺកូវីដ-១៩ ។

**ប្រការ៣ ..**

ប្រកាសអន្តរក្រសួងនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០២១ តទៅ។

**ប្រការ៤ ..**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងសុខាភិបាល ប្រធានគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ ប្រធានអនុគណៈកម្មការជំនាញក្រោមចំណុះគណៈកម្មការអន្តរក្រសួងប្រយុទ្ធនឹងជំងឺកូវីដ-១៩ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃសៅរ៍ ៥ រោច ខែស្រាពណ៍ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**ម៉ម ប៊ុនហេង**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩ (គ.ប.ក)
- យន្តការចំណុះឱ្យគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩ (គ.ប.ក)
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



Scanned with CamScanner